ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ....០១...សរណន

# សារាចរណែនាំ

## ស្តីអំពី

## ការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង
## តាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ

អនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ និងអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ សវនកម្មផ្ទៃក្នុងត្រូវបានបង្កើត និងដំណើរការបានមួយចំនួនធំហើយ ។

នៅក្នុងការអនុវត្តមុខងាររបស់ខ្លួនកន្លងមក ក្រៅពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួងស្ថាប័នមួយចំនួន នៅជួបការលំបាកពាក់ព័ន្ធនឹងទីតាំង ធនធានមនុស្ស សំភារៈ និងជំនាញ ជាពិសេស គឺការបែងចែកភារកិច្ចរវាងសវនកម្មផ្ទៃក្នុងជាមួយនិងអគ្គាធិការដ្ឋាន ឬអធិការដ្ឋាន ។ ប្រការនេះធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារសវនកម្មផ្ទៃក្នុង ។

អាស្រ័យហេតុនេះ ដើម្បីដោះស្រាយរាល់ការលំបាកខាងលើ និងជំរុញឱ្យសវនកម្មផ្ទៃក្នុងបំពេញតួនាទីរបស់ខ្លួនបានពេញលេញ ជាពិសេសរួមចំណែកធានាជោគជ័យ ជូនដល់កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ២ " **បង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** " ដែលរាជរដ្ឋាភិបាលទើបប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ កន្លងទៅនេះ រាជរដ្ឋាភិបាលសូមណែនាំដូចខាងក្រោម :

១- ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈណា ដែលមិនទាន់បង្កើតសវនកម្មផ្ទៃក្នុង ត្រូវបង្កើតសវនកម្មផ្ទៃក្នុង

២- ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវយកចិត្តទុកដាក់ផ្តល់ទីតាំង បំពាក់សំភារៈបរិក្ខារចាំបាច់ ផ្តល់ធនធានមនុស្សសមស្រប និងសំរួលដល់កិច្ចដំណើរការសវនកម្មផ្ទៃក្នុង

៣- ក្រសួង ស្ថាប័ននីមួយៗត្រូវសម្របសម្រួលបែងចែកភារកិច្ចរវាងអគ្គាធិការដ្ឋានឬអធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងឱ្យបានសមស្រប ដោយអនុលោមតាមមាត្រា ៩ ជំពូកទី ៥ នៃអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាក្រសួងនាំមុខ ត្រូវផ្តល់ជូននូវលិខិតបទដ្ឋានគតិយុត្តិ និងបច្ចេកទេស ការបណ្តុះបណ្តាលជំនាញ និងចែករំលែកបទពិសោធនៃការងារពាក់ព័ន្ធសវនកម្មផ្ទៃក្នុង ដល់សវនកម្មផ្ទៃក្នុងគ្រប់ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពការងារសវនកម្មនៃក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈទាំងនោះ

៥- ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈទាំងអស់ ត្រូវពង្រីកនិងពង្រឹងកិច្ចសហប្រតិបត្តិការរវាងគ្នាជុំវិញការងារសវនកម្មផ្ទៃក្នុង ជាពិសេសការផ្លាស់ប្តូរព័ត៌មាន និងទិន្នន័យចាំបាច់នានា រួមទាំងការគិតគូរអំពីការលើកទឹកចិត្តឱ្យបានសមស្របជូនសវនករផងដែរ ។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈទាំងអស់ត្រូវយកចិត្តទុកដាក់សហការអនុវត្តឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចំលងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ

"ដើម្បីសហការអនុវត្ត"

-ឯកសារ-កាលប្បវត្តិ